**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៧០ អ.ក
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមលេខ ០៧១ ស.ព្រ.ណ/២៣
ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល ។

កាលបរិច្ឆេទសវនាការ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ និង ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ។

កាលបរិច្ឆេទការប្រកាសសាលក្រមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

## ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៧០ អ.ក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] វុទ្ធី ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងភ្លើង មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តស្វាយរៀង និង ទីលំនៅបច្ចុប្បន្ននៅភូមិផ្ទះលេខ៨៧៤ ភូមិក្រពើហា សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] វណ្ណៈ "រ" ម្ដាយឈ្មោះ [redacted] ស៊ីរឿន "រ" ប្រពន្ធឈ្មោះ [redacted] អូន មានកូនចំនួន ០១នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ត្រូវបានជាប់ចោទពី **បទរំលោភលើលំនៅដ្ឋាន បទមិនអនុវត្តសេចក្ដីសម្រេចរបស់តុលាការ និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល និង នៅភូមិព្រែកឡុង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល នៅអំឡុងឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៩៩ មាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ។

ដើមបណ្ដឹង (អ្នកដាក់ពាក្យបណ្ដឹង) ៖

១. ឈ្មោះ [redacted] សារ៉ាយ ភេទស្រី អាយុ ៥០ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

២. ឈ្មោះ [redacted] ប៊ីណា ភេទស្រី អាយុ ២៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីទូច ភេទស្រី អាយុ ៣៩ឆ្នាំ សញ្ជាតិខ្មែរ កាត់លិខិតឆ្លងដែនសញ្ជាតិខ្មែរលេខ N1853014 ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ទីលំនៅបច្ចុប្បន្ននៅ ៦/៣ Simmons Court South Yarra Melbourne Postcode 3141 ប្រទេសអូស្ត្រាលី ។

មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ស្រីទូច ។

- បានឃើញ ដីកាដំណោះស្រាយលេខ ៨០៩ ដកដស ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

នៅអំឡុងឆ្នាំ២០២១ មានករណីរំលោភលើលំនៅដ្ឋាន មិនអនុវត្តសេចក្ដីសម្រេចរបស់តុលាការ និង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត កើតឡើងនៅចំណុចភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល និង នៅភូមិព្រែកឡុង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានចូលទៅគ្រប់គ្រង និង រស់នៅក្នុងដីផ្ទះពីរទីតាំងខាងលើដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សារ៉ាយ និង ឈ្មោះ [redacted] ប៊ីណា ជាដើមបណ្ដឹងរដ្ឋប្បវេណីដោយគ្មានការអនុញ្ញាតពីម្ចាស់ផ្ទះសោះ ។ មិនតែប៉ុណ្ណោះជនជាប់ចោទបានហាមឃាត់ និង ដេញអ្នកតំណាងរបស់ម្ចាស់មិនឱ្យចូល រួចហើយថែមទាំងប្ដឹងសុំឱ្យសាលាដំបូងខេត្តកណ្ដាល ចេញដីការក្សាការពារហាមឃាត់មិនឱ្យម្ចាស់ផ្ទះចូល ។ ដោយសារតែទទួលរងនូវការរំលោភបំពានសិទ្ធិ និង ភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរបែបនេះ ទើបដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងសុំទៅសាលាដំបូងខេត្តកណ្ដាល ឱ្យលុបចោលដីកាសម្រេចរក្សាការពារនោះចោលវិញ ដោយយោងលើឯកសារភស្តុតាងយ៉ាងរឹងមាំពាក់ព័ន្ធនឹងដីផ្ទះទាំងពីរខាងលើ គឺប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ០១៨១០៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ បន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ពាក្យបណ្ដឹងសុំអនុវត្តដីកាសម្រេចនេះទៅអាជ្ញាសាលាខេត្តកណ្ដាល ដើម្បីចុះអនុវត្ត។ នៅអំឡុងពេលចុះអនុវត្តខាងជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានសំណូមពរមកខាងមន្ត្រីអាជ្ញាសាលា និង គណៈកម្មការចម្រុះទុករយៈពេលឱ្យខ្លួន១សប្តាហ៍ដើម្បីរុះរើឥវ៉ាន់ចេញ លុះដល់ពេលកំណត់ជនជាប់ចោទនៅតែមិនព្រមចេញ និង បន្តធ្វើសកម្មភាពរំលោភច្បាប់ ដូចមុនអញ្ចឹង ដែលទង្វើនេះ បង្ហាញឱ្យឃើញពីចេតនាមិនគោរពសេចក្ដីសម្រេចរបស់តុលាការ ការរំលោភបំពានកម្មសិទ្ធិដីលំនៅដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងធ្ងន់ធ្ងរ និង មិនកោតខ្លាចច្បាប់អ្វីបន្តិចសោះ ហើយជនជាប់ចោទនៅតែព្យាយាមចង់រស់នៅ និង ចង់បានដីផ្ទះពីរទីតាំងខាងលើយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ទាំងដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញឯកសារប្លង់រឹងយ៉ាងណាក៏ដោយ។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយនៅចំពោះមុខតុលាការថា ៖ ខ្ញុំបានដឹងពីការចោទប្រកាន់ពីបទរំលោភលើលំនៅដ្ឋាន បទមិនអនុវត្តសេចក្ដីសម្រេចរបស់តុលាការ និង បទហិង្សាទៅលើអ្នក



Scanned with CamScanner

កាន់កាប់អចលនវត្ថុដោយសុចរិត ប៉ុន្តែខ្ញុំសុំបដិសេធចោលការចោទប្រកាន់ទាំងនោះ ដីលំនៅដ្ឋានទាំងពីរកន្លែងដែលគេចោទប្រកាន់ខ្ញុំបាទ បទរំលោភលើលំនៅដ្ឋាន បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត នោះជាដីរបស់ឈ្មោះ [redacted] Trickey ដែលគាត់បានទិញនៅក្នុងអំឡុងឆ្នាំ ២០១១ និង ឆ្នាំ២០១២ ហើយ ដោយឈ្មោះ [redacted] Trickey ជាជនបរទេស មិនអាចដាក់ឈ្មោះទិញដីបាន ក៏បានដាក់ឈ្មោះប្អូនថ្លៃឈ្មោះ [redacted] ស្រីទូច នៅក្នុងប័ណ្ណសំគាល់សិទ្ធិទាំងពីរនោះ ។ ឈ្មោះ [redacted] Trickey ក្រោយពីទិញដីទាំងពីរកន្លែងនោះហើយ គាត់បានធ្វើផ្ទះសម្រាប់ស្នាក់នៅ នៅលើដីដែល មានប័ណ្ណសំគាល់សិទ្ធិលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ សម្រាប់គាត់រស់នៅ និង ដីមួយកន្លែងទៀតដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ គាត់សាងសង់ជាក្លឹបហាត់កីឡាប្រដាល់ សម្រាប់ទទួលក្មេងៗ មកហាត់ដោយមិនគិតប្រាក់ ហើយឈ្មោះ [redacted] Trickey បានយកខ្ញុំធ្វើជាប្រធានក្លឹប ហើយខ្ញុំក៏បានស្នាក់នៅ និង គ្រប់គ្រងក្លឹបប្រដាល់នោះតាំង ពីឆ្នាំ២០១២ មករហូតដល់បច្ចុប្បន្ន ។ លុះក្រោយមក ខ្ញុំពុំបានចាំខែឆ្នាំ ឈ្មោះ [redacted] Trickey បានលែងលះគ្នាជាមួយឈ្មោះ [redacted] ស្រីទូច ដែលត្រូវជាប្អូនថ្លៃរបស់ឈ្មោះ Justin Trickey បន្ទាប់ពីលែងលះគ្នាបានឱ្យឈ្មោះ [redacted] ស្រីទូច មកផ្ទេរឈ្មោះនៅក្នុងប័ណ្ណសំគាល់កាន់កាប់ដីទាំងពីរកន្លែង ពីឈ្មោះ [redacted] ស្រីទូច មកឈ្មោះ [redacted] សារ៉ុម វិញ ដែលត្រូវជាមិត្តភក្តិរបស់ឈ្មោះ Justin Trickey ប៉ុន្តែឈ្មោះ [redacted] ស្រីទូច ពុំបានចូលខ្លួនមកផ្ទេរកម្មសិទ្ធិដីនោះទេ បែរជាឱ្យឈ្មោះ [redacted] សារ៉ាយ ប្តីឈ្មោះ [redacted] ឈាង ព្រមទាំងកូនៗ មករស់នៅក្នុងផ្ទះរបស់ឈ្មោះ Justin Trickey នៅពេលនោះ ដោយឈ្មោះ [redacted] Trickey ត្រូវទៅព្យាបាលជំងឺនៅអូស្ត្រាលី ក៏បានផ្ទេរសិទ្ធិឱ្យទៅឈ្មោះ ឈាន សារ៉ុម ធ្វើជាតំណាងប្តឹងមកសាលាដំបូងខេត្តកណ្តាល សុំដីកាសម្រេចរក្សាការពារហាមឃាត់ មិនឱ្យឈ្មោះ [redacted] ស្រីទូច ចាត់ចែងជាបណ្តោះអាសន្ននៅលើដី និង ផ្ទះ ដែលមានប័ណ្ណសំគាល់កាន់កាប់ដីធ្លីលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ បន្ទាប់មកសាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចរក្សាការពារ ហើយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ អាជ្ញាសាលា ក៏បានចុះទៅអនុវត្តដីកាសម្រេចរក្សាការពារ នៅពេលនោះ ឈ្មោះ [redacted] សារ៉ាយ និង ប្តីឈ្មោះ [redacted] ឈាង ព្រមទាំងកូនៗ បានចុះចេញពីផ្ទះ និង ដីនោះ ដោយយកសំភារៈប្រើប្រាស់របស់ឈ្មោះ [redacted] Trickey ទៅទាំងអស់ ។ លុះក្រោយមកទៀតឈ្មោះ [redacted] Trickey បានឱ្យឈ្មោះ [redacted] សារ៉ុម ដាក់ពាក្យបណ្តឹងអង្គសេចក្តីមកសាលាដំបូងខេត្តកណ្តាល ហើយលោកចៅក្រមសាលាដំបូងខេត្តកណ្តាល បានចេញសេចក្តីសម្រេចដោយមានខ្លឹមសារ មោឃភាពប័ណ្ណលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ស្រីទូច ហើយទទួលស្គាល់តំណាងដើមចោទឈ្មោះ [redacted] សារ៉ុម ជាម្ចាស់កម្មសិទ្ធិលើដីទាំងពីរកន្លែង ដែលមានលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ហើយសាលក្រមបានចូលជាស្ថាពរ ហើយបច្ចុប្បន្ន កំពុងអនុវត្តផ្ទេរឈ្មោះ នៅក្នុងប័ណ្ណសំគាល់សិទ្ធិ ទាំងពីរកន្លែង ដែលមានលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ តាមសាលក្រមស្ថាពររួចហើយ ប៉ុន្តែពុំបានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីថ្មីនៅឡើយទេ ។ អាជ្ញាសាលាចុះអនុវត្តនោះ ខ្ញុំបានសំណូមពរ និង បានសន្យាចំពោះមុខអាជ្ញាធរថា



Scanned with CamScanner

នឹង រុះរើឥវ៉ាន់ចេញក្នុងរយៈពេលមួយសប្តាហ៍ លុះដល់ពេលមួយសប្តាហ៍នេះមក គឺខ្ញុំមិនបានឃើញ អាជ្ញាសាលាចុះមកទៀត ទើបខ្ញុំនៅចេញចូលបន្តទៀត ។ ប៉ុន្តែខ្ញុំមិនបាននៅក្នុងផ្ទះនោះទេ គឺមាន តែប្អូនរបស់ខ្ញុំ ឈ្មោះ [redacted] ណារីន ដែលរស់នៅទីតាំងនោះ ។

២. ដើមបណ្តឹង (សាក្សី) ឈ្មោះ [redacted]សារ៉ាយ បានឆ្លើយនៅចំពោះមុខតុលាការថា ៖ នៅក្នុងរឿងនេះ ខ្ញុំដឹងថា ទីតាំងដី និង ផ្ទះ ទាំងពីរកន្លែងនោះ ជារបស់ប្អូនស្រីរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ហើយត្រូវបាន គេចូលមករំលោភបំពាន ក្នុងផ្ទះរបស់ប្អូនស្រីខ្ញុំ ។ ខ្ញុំមិនដែលមានវិវាទជាមួយឈ្មោះ [redacted] វុទ្ធី នោះទេ គឺគ្រាន់តែខ្ញុំដឹងលឺ ពីប្អូនស្រីរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ។ ខ្ញុំបានឃើញឈ្មោះ [redacted] វុទ្ធី ធ្វើការ ជាមួយប្អូនស្រីខ្ញុំ តែមិនស្គាល់គាត់ច្បាស់នោះទេ ។ ឈ្មោះ [redacted] វុទ្ធី គឺប្អូនស្រីរបស់ខ្ញុំជាអ្នកណែនាំ ឱ្យស្គាល់ឈ្មោះ [redacted] ត្រីកគី ([redacted] Trickey) ។ កន្លែងប្រដាល់ដែលកសាងនៅលើដីរបស់ ប្អូនស្រីខ្ញុំនោះ គឺបានកសាងជាកន្លែងប្រដាល់រួចរាល់ ទើបបានឈ្មោះ [redacted] វុទ្ធី ចូលមកមើលការ ខុសត្រូវនៅកន្លែងទាំងនោះ ។ ប្អូនស្រីរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ជាម្ចាស់កម្មសិទ្ធិទាំងពីរកន្លែង តាមរយៈប័ណ្ណកម្មសិទ្ធិនេះ ។ ខ្ញុំមិនបានដឹងថាប័ណ្ណទាំងពីរនេះត្រូវបានតុលាការមោឃភាពនោះ ទេ ។ ខ្ញុំបានដាក់ពាក្យបណ្តឹងជំនុំជម្រះសារជាថ្មីនៅសាលាដំបូងខេត្តកណ្តាល តែខ្ញុំមិនបានដឹង ថា សាលាឧទ្ធរណ៍បានបដិសេធវិញនោះទេ ។ នៅពេលក្លឹបប្រដាល់នោះបានសាងសង់រួចរាល់ ទើបបានឃើញឈ្មោះ [redacted] វុទ្ធី ចេញចូលក្នុងក្លឹបនោះ ។ ក្លឹបនោះបានសាងសង់រួចរាល់នៅឆ្នាំ ២០១៤ ។ ពេលដែលឈ្មោះ [redacted] វុទ្ធី ចូលមកនៅក្នុងក្លឹបនោះ គឺប្អូនស្រីខ្ញុំឈ្មោះ [redacted] ស្រីទូច បានដឹងថាឈ្មោះនេះចូលនៅ។ ក្នុងឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៩ ឈ្មោះ [redacted] វុទ្ធី មករស់នៅក្នុង ក្លឹប ។ នៅក្នុងឆ្នាំ២០២១ និង ឆ្នាំ២០២២ ប្អូនស្រីខ្ញុំមិនបានដឹងថាឈ្មោះ [redacted] វុទ្ធី ចូលរស់នៅ ក្នុងក្លឹបនោះទេ ។

៣. ដើមបណ្តឹង (សាក្សី) ឈ្មោះ [redacted]បីណា បានឆ្លើយនៅចំពោះមុខតុលាការថា ៖ ខ្ញុំជាអ្នកដាក់ពាក្យ បណ្តឹងជំនួសម្តាយមីងរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ។ ខ្ញុំត្រូវជាក្មួយរបស់ឈ្មោះ [redacted] ស្រីទូច ។ ខ្ញុំ រស់នៅជាមួយមីងខ្ញុំឈ្មោះ [redacted] ស្រីទូច តាំងពីតូច គឺមីងរបស់ខ្ញុំមានផ្ទះចំនួនពីរកន្លែងនៅ ក្រុងតាខ្មៅ ។ គាត់ជាអ្នករកស៊ី ។ ខ្ញុំមិនបានចាំច្បាស់ថាឈ្មោះ [redacted] វុទ្ធី បានមករស់នៅក្នុងផ្ទះនោះ ក្នុងឆ្នាំណានោះទេ ។ ដំបូងឡើយគឺមីងខ្ញុំបានអនុញ្ញាតឱ្យឈ្មោះ [redacted] វុទ្ធី ចេញចូលនៅក្នុងផ្ទះនោះ មិនមែនឱ្យស្នាក់នៅក្នុងផ្ទះនោះទេ ។ ខ្ញុំមិនចាំថាឈ្មោះ [redacted] វុទ្ធី ស្នាក់នៅលើដីដែលមានវិវាទ គឺនៅក្នុងឆ្នាំណាគឺមិនចាំនោះទេ តែបច្ចុប្បន្នគឺលោក [redacted] វុទ្ធី កំពុងស្នាក់នៅលើដីនោះតែម្តង មិនមែនចេញចូលដូចមុនទេ ។ គាត់រស់នៅលើទីតាំងដីផ្ទះនោះទាំងពីរទីតាំងតែម្តង ។ ការរស់នៅ របស់គាត់ មិនមានការអនុញ្ញាតពីមីងរបស់ខ្ញុំនោះទេ គឺគាត់ចូលនៅក្នុងផ្ទះទាំងពីរនោះតែម្តង ។ ដីនោះគឺមានឈ្មោះមីងរបស់ខ្ញុំ ឈ្មោះ [redacted] ស្រីទូច នៅក្នុងប័ណ្ណកម្មសិទ្ធិ ។ នៅពេលអាជ្ញាធរចុះ ទៅអនុវត្តដីកា សម្រេចលុបចោលដីកាសម្រេចរក្សាការពារ ឈ្មោះ [redacted] វុទ្ធី បានសំណូមពរសុំ អាជ្ញាធររយៈពេលមួយសប្តាហ៍ ដើម្បីធ្វើការរុះរើសម្ភារៈចេញពីទីតាំងដីនោះ ប៉ុន្តែដល់ពេលកំណត់ ឈ្មោះ [redacted] វុទ្ធី មិនបានរើចេញពីផ្ទះនោះទេ ។ ប្តីរបស់មីងខ្ញុំ គឺឈ្មោះ [redacted] Trickey ប្តីរបស់ មីងខ្ញុំបានឈប់រស់នៅជាប្តីប្រពន្ធ ។ ខ្ញុំមិនបានដឹងថាសាលក្រមដែលសម្រេចលែងលះ និង ទ្រព្យ សម្បត្តិរវាងឈ្មោះ Anton និង មីងខ្ញុំនៅប្រទេសអូស្ត្រាលីនោះ គឺខ្ញុំមិនបានដឹងនោះទេ ។ នៅថ្ងៃ អាជ្ញាធរចុះទៅអនុវត្តដីកាសម្រេចលុបដីកាសម្រេចរក្សាការពារនោះ ខ្ញុំមិនបានដឹងថាប្លង់ដីទាំងពីរ នោះត្រូវបានមោឃភាព ឬ មិនមោឃភាពនោះទេ ។ នៅថ្ងៃអាជ្ញាធរចុះអនុវត្តនោះ គឺខ្ញុំមាន

វត្ថុមាននៅទីនោះ ប៉ុន្តែមីងរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ដែលមានឈ្មោះជាម្ចាស់កម្មសិទ្ធិលើដីនោះ មិនមានវត្តមាន នៅទីតាំងនោះទេ ។

៤. លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំជាមេធាវីការពារសិទ្ធិឱ្យលោកស្រី [redacted] ស្រីទូច ខ្ញុំយល់ឃើញថា លោកស្រី [redacted] ស្រីទូច ជាម្ចាស់កម្មសិទ្ធិលើដីចំនួនពីរកន្លែង ដែលមានទីតាំងស្ថិតនៅក្នុងភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល មានទំហំ ១.១៩១ (មួយពាន់មួយរយកៅសិបមួយ) ម៉ែត្រការ៉េ និង ទីតាំងទី២ នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល មានទំហំ ៦៧៨ (ប្រាំមួយរយចិតសិបប្រាំបី) ម៉ែត្រការ៉េ ហើយដីទាំងពីរទីតាំងនេះមានឈ្មោះ នួន ស្រីទូច ជាម្ចាស់កម្មសិទ្ធិ ។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា ទំនាស់រវាងឈ្មោះ [redacted] ស្រីទូច និង ឈ្មោះ [redacted] ទ្រីកគី គឺកើតឡើងដោយសារការពាក់ព័ន្ធទៅនឹងការចូលកាន់កាប់លោក [redacted] វុទ្ធី ដែលជាអ្នកពុំមានសិទ្ធិក្នុងការចូលកាន់កាប់ដី ។ លោក [redacted] វុទ្ធី បានចូលកាន់កាប់ដីទាំងពីរទីតាំង ដោយគ្មានការអនុញ្ញាតពីដើមបណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងវិញទៀត លោក [redacted] វុទ្ធី មិនអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធ នឹងការអនុវត្តរបស់មន្ត្រីអាជ្ញាសាលាចុះទៅលុបចោលដីកាសម្រេចរក្សាការពារ គឺលោក [redacted] វុទ្ធី បានស្នើសុំមន្ត្រីអាជ្ញាសាលាទុករយៈពេលមួយសប្តាហ៍ ដើម្បីអាចឱ្យគាត់រើសម្ភារៈរបស់គាត់ចេញពី ទីតាំងដែលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្ត ប៉ុន្តែដល់ពេលកំណត់លោក [redacted] វុទ្ធី មិនបានរើចេញពីទីតាំងនោះទេ ហើយថែមទាំងប្រាប់ឱ្យគូកនរបស់គាត់ឈ្មោះ [redacted] ណារីន ចូលទៅរស់នៅ និង កាន់កាប់ក្នុងទីតាំងដីដែលជាកម្មសិទ្ធិរបស់កូនក្តីរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច ។ ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា ដោយផ្អែកលើការអះអាងរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា លោក [redacted] វុទ្ធី បានចូលកាន់កាប់ក្នុងទីតាំងដីនោះតាមរយៈលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ [redacted] ទ្រីកគី ប៉ុន្តែបើយើងពិនិត្យទៅលើខ្លឹមសារនៃលិខិតប្រគល់នោះគឺមានភាពផ្ទុយគ្នា ដោយលិខិតនោះធ្វើឡើងជា ភាសាអង់គ្លេស ហើយខ្លឹមសារនោះគឺឈ្មោះ [redacted] ទ្រីកគី បានអះអាងថាខ្លួនជាម្ចាស់កម្មសិទ្ធិ នៅលើទីតាំងដីនោះ ប៉ុន្តែផ្ទុយទៅវិញកូនក្តីខ្ញុំជាអ្នកមានឈ្មោះនៅក្នុងប័ណ្ណកម្មសិទ្ធិនោះ កូនក្តីរបស់ខ្ញុំនៅតែជាម្ចាស់កម្មសិទ្ធិនៅលើទីតាំងដីនោះ ។ នាងខ្ញុំតំណាងឱ្យកូនក្តីរបស់ខ្ញុំស្នើសុំឱ្យតុលាការផ្តន្ទាទោស ជនជាប់ចោទ និង ទាមទារសំណងចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិកគត់ ។

៥. លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីទូច ខ្ញុំគាំទ្រការលើកឡើងរបស់សហភាតាខ្ញុំ និង ស្នើសុំបន្ថែមពីលើសហភាតារបស់ខ្ញុំ ក្រោយពីបានស្តាប់ចម្លើយរបស់ លោក [redacted] វុទ្ធី គឺអាចបញ្ជាក់ថា លោក [redacted] វុទ្ធី ពិតជាបានដឹងថាអំពីដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ លេខ ០៦ "ឆ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ដើម្បីរំលាយការកាន់កាប់របស់ជនជាប់ចោទ ឈ្មោះ [redacted] វុទ្ធី វិញ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានសំណូមពរ និង សន្យាជាមួយមន្ត្រីអាជ្ញាសាលា ដែលបានចុះទៅអនុវត្តសេចក្តីសម្រេចលុបដីកាសម្រេចរក្សាការពារ ដើម្បីឱ្យមន្ត្រីអាជ្ញាសាលាទុករយៈពេលឱ្យខ្លួនមួយសប្តាហ៍ ដើម្បីរើសម្ភារៈចេញពីទីតាំងដែលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តនោះ ។ ផ្ទុយទៅវិញក្រោយដល់កាលកំណត់ដែលជនជាប់ចោទបានស្នើសុំ ដើម្បីរើសម្ភារៈចេញពីទីតាំងនោះ បែរជាជនជាប់ចោទមិនគោរព និង អនុវត្តតាមការសន្យារបស់ខ្លួន ដើម្បីរើសម្ភារៈចេញពីទីតាំងនោះ ហើយបន្ថែមពីនោះទៀត



Scanned with CamScanner

ជនជាប់ចោទបានបញ្ជាឱ្យបក្សពួករបស់ខ្លួន បន្តស្នាក់នៅលើទីតាំងនោះដដែល ត្រង់ចំណុចនេះ យើងអាចមើលឃើញថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ពិតជាបានប្រព្រឹត្តបទមិនអនុវត្តតាមសេចក្តីសម្រេចតុលាការ ប្រាកដមែន ។ ដោយឡែក ចំពោះការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដោយបានលើកឡើងអំពីសាលក្រម លិខិតបញ្ជាក់ស្ថាពរ និង រូបមន្តអនុវត្ត ។ ត្រង់ចំណុចនេះ សូមបញ្ជាក់ថា សាលក្រមលើអង្គសេចក្តី ក៏ដូចជាឯកសារគតិយុត្តិដទៃទៀត ដែលលោកមេធាវីការពារសិទ្ធិជនជាប់ចោទ បានអះអាងថាជនជាប់ចោទជាម្ចាស់កម្មសិទ្ធិ គឺមិនត្រឹមត្រូវនោះទេ ។ ចំពោះប័ណ្ណសម្គាល់កម្មសិទ្ធិអចលនវត្ថុទាំងពីរប័ណ្ណរបស់កូនក្តីខ្ញុំឈ្មោះ [redacted] ស្រីទូច គឺនៅតែមានសុពលភាព និង ពុំទាន់និរាករណ៍លើប័ណ្ណកម្មសិទ្ធិរបស់កូនក្តីខ្ញុំនៅឡើយ ដរាបណាដែលមន្ត្រីសុរិយោដីមិនទាន់បានធ្វើលេខាចារិក ប្តូរឈ្មោះពីបុគ្គលណាម្នាក់ ទៅបុគ្គលណាម្នាក់នោះ បុគ្គលដែលឈ្មោះក្តីនៅមិនទាន់ក្លាយជាម្ចាស់កម្មសិទ្ធិ នៅលើទីតាំងអចលនវត្ថុ នោះនៅឡើយទេ ។ ម្យ៉ាងវិញទៀតនៅពេលដែលកូនក្តីខ្ញុំបានដឹងដំណឹងអំពីលិខិតជូនដំណឹង លេខ ១៥៤ ល.ដ.ណ/២១ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់អាជ្ញាសាលានៃសាលាដំបូងខេត្តកណ្តាល កូនក្តីរបស់ខ្ញុំបានប្តឹងសុំផ្អាកការអនុវត្តរបស់អាជ្ញាសាលានៃសាលាដំបូងខេត្តកណ្តាលជាបណ្តោះអាសន្ន និង បានប្តឹងសុំទាមទារឱ្យតុលាការជំនុំជម្រះសារជាថ្មី នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ដូចនេះពុំមានការអនុវត្តសាលក្រមស្ថាពរណាមួយកើតឡើងនោះទេ ។ ត្រង់ចំណុចនេះអាចបញ្ជាក់បានថា កូនក្តីរបស់ខ្ញុំឈ្មោះ [redacted] ស្រីទូច នៅតែជាម្ចាស់កម្មសិទ្ធិករលើទីតាំងអចលនវត្ថុ ទាំងពីរកន្លែងនោះដដែល ហើយជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ពិតជាបានប្រព្រឹត្តបទរំលោភលើលំនៅដ្ឋាន និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រាកដមែន ។ នាងខ្ញុំតំណាងឱ្យកូនក្តីរបស់ខ្ញុំស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ទៅតាមច្បាប់ពី បទរំលោភលើលំនៅដ្ឋាន បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ និង បទហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និង ស្នើសុំទាមទារសំណងចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិកគត់ ។

៦. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ក្រោយពីបញ្ចប់កិច្ចពិភាក្សាដេញដោល ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ តំណាងអយ្យការធ្វើការកត់សម្គាល់ខ្លីៗ និង សន្និដ្ឋានដូចតទៅ ១. ភស្តុតាងបញ្ជាក់សិទ្ធិកម្មសិទ្ធិ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញប័ណ្ណកម្មសិទ្ធិ ចំនួន ២សន្លឹក ចំណែកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានលើកឡើងអំពីសាលក្រម លិខិតបញ្ជាក់ស្ថាពរ និង រូបមន្តអនុវត្ត ។ ត្រង់ចំណុចនេះ សូមបញ្ជាក់ថា សាលក្រមលើអង្គសេចក្តី ក៏ដូចជាឯកសារគតិយុត្តិដទៃទៀត ដែលលោកមេធាវីការពារសិទ្ធិជនជាប់ចោទ ដែលអះអាងថាជនជាប់ចោទជាម្ចាស់កម្មសិទ្ធិគឺមិនត្រឹមត្រូវនោះទេ ។ នៅពេលមន្ត្រីសុរិយោដីមិនបានធ្វើលេខាចារិក ប្តូរឈ្មោះ ពីបុគ្គលណាម្នាក់ទៅបុគ្គលណាម្នាក់នោះ បុគ្គលដែលឈ្មោះក្តីមិនទាន់ជាម្ចាស់កម្មសិទ្ធិនៅលើទីតាំងអចលនវត្ថុនោះទេ ។ ដីកាសម្រេចរក្សាការពារមិនបាត់បង់អានុភាពដោយស្វ័យប្រវត្តិនោះទេ គឺបាត់បង់អានុភាពនៅពេលមានដីកាសម្រេចមួយផ្សេងលុបដីកាសម្រេចដើម ។ ប្រសិនបើមិនទាន់មានដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារនោះ មន្ត្រីសុរិយោដីមិនអាចធ្វើលេខាចារិកផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះបានទេ ។ រឿងក្តីនេះចំណុចដែលសំខាន់បំផុតនៅត្រង់ថា ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារមានអានុភាព អនុវត្តដល់កម្រិតណា ។ បណ្តឹងអង្គសេចក្តីក្នុងសំណុំរឿងរដ្ឋប្បវេណី និង សំណុំរឿង



Scanned with CamScanner

រក្សាការពារជាសំណុំរឿងពីរដោយឡែកពីគ្នា ។ អំពើមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលការផ្តន្ទាទោសអំពីបទល្មើសនេះ ពាក់ព័ន្ធនឹងនិតិវិធី ហើយតាមការពិភាក្សាដេញដោល ឃើញថាពិតជាមានការមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលជាដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ។ ដីកាសម្រេចរក្សាការពាររបស់តុលាការ គឺអាចមានខ្លឹមសារពីរចំណុច ១. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទវិវាទ ២. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ពោលគឺអនុញ្ញាតឱ្យម្ចាស់បំណុលរបស់ដីកាសម្រេចរក្សាការពារ ចូលរស់នៅលើទីតាំងដីនោះបាន ។ ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ បានសម្រេចលុបចោលដីកាសម្រេចរក្សាការពារលើកមុន ដែលនាំឱ្យមានខ្លឹមសារសរុបជារួមថាម្ចាស់បំណុលនៃ ដីកាសម្រេចរក្សាការពារចេញពីទីតាំងដីមានវិវាទ ។ អាជ្ញាសាលាបានចុះទៅអនុវត្តដើម្បីរំលាយការកាន់កាប់របស់ម្ចាស់បំណុល (រំលាយការកាន់កាប់របស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី) ប៉ុន្តែនៅពេលដែលចុះទៅរំលាយការកាន់កាប់ ជនជាប់ចោទបានស្នើសុំអនុញ្ញាតមួយសប្តាហ៍ ដើម្បីធ្វើការចាកចេញដោយស្ម័គ្រចិត្ត ។ ជនជាប់ចោទជាអ្នកបំពាន ទៅលើការចុះអនុវត្តរបស់អាជ្ញាសាលា ដែលមិនព្រមចុះចេញពីទីតាំងដី ក្រោយពេលមានការចុះអនុវត្តរបស់អាជ្ញាសាលាចប់សព្វគ្រប់ ។ កំណត់ហេតុរបស់អាជ្ញាសាលាបានសរសេរយ៉ាងច្បាស់លាស់ថា ជនជាប់ចោទបានស្នើសុំឱ្យទុកពេលមួយសប្តាហ៍ ដែលមានន័យថា កាលអនុវត្តចប់សព្វគ្រប់ហើយ ។ ការលើកឡើងរបស់ជនជាប់ចោទថាមិនឃើញអាជ្ញាសាលាមិនចុះទៅម្តងទៀត ទើបមិនព្រមចាកចេញ ជាមូលហេតុដែលមិនសមរម្យ ដោយជនជាប់ចោទបានស្នើសុំរយៈពេល ដើម្បីចាកចេញរួចហើយ ហើយក៏មិនទាមទារឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅនឹងកន្លែងអនុវត្ត ដើម្បីប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីទេ ។ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទ បានប្រព្រឹត្តបទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដោយមានភស្តុតាងស៊ីសង្វាក់គ្នា ។ ដោយឡែកចំពោះបទរំលោភលើលំនៅដ្ឋាន និង បទប្រើប្រាស់អំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ឃើញថា តាមភស្តុតាងនានាក្នុងសំណុំរឿង ពុំមានភស្តុតាងចង្អុលបង្ហាញថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសទេ ហើយជនជាប់ចោទបានចូលទៅកាន់កាប់ និង បានកសាងកន្លែងប្រដាល់ នាំឱ្យមិនមានបទល្មើស បទរំលោភលើលំនៅដ្ឋាន និងបទអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុទេ ដែលគួរពិនិត្យសម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់នេះ ។ តំណាងអយ្យការប្តឹងសុំផ្តន្ទាទោស លើជនជាប់ចោទពី បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ និង ស្នើសុំតុលាការសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ពីរ គឺ បទរំលោភលើលំនៅដ្ឋាន និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ។

៧. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាដំណោះស្រាយ បានចោទប្រកាន់មកលើកូនក្តីរបស់ខ្ញុំបាទ ដោយសំអាងលើអង្គហេតុថា កាលពីអំឡុងឆ្នាំ២០២១ មានករណីរំលោភលើលំនៅដ្ឋាន មិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ និង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត កើតឡើងនៅចំណុចភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយតំណាងអយ្យយការ និង ចៅក្រមស៊ើបសួរបានចោទប្រកាន់ លើកូនក្តីខ្ញុំឈ្មោះ [redacted] វុទ្ធី បានចូលទៅគ្រប់គ្រង និង រស់នៅក្នុងដីផ្ទះពីរទីតាំងខាងលើដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ស្រីទូច ។ ដូចនេះ ដើម្បីឆ្លើយបំភ្លឺទៅលើការចោទប្រកាន់ទាំងបីខាងលើ ដោយសារតែបទចោទទាំងបីខាងលើនេះ គឺពាក់ព័ន្ធទៅនឹងអចលនទ្រព្យដូចនេះ ខ្ញុំនឹងជម្រាបជូនលោកចៅក្រម



Scanned with CamScanner

ថាតើការចោទប្រកាន់នេះត្រឹមត្រូវឬអត់? ឆ្លងតាមរយៈការដេញដោលក្នុងសវនាការ នៅក្នុងសំណុំរឿងនេះ ទំនាក់ទំនងគឺរវាងឈ្មោះ [redacted] ស្រីទូច និង ប្តីរបស់គាត់ ឈ្មោះ [redacted] ទ្រិកគី ([redacted] Trickey) ដែលឈ្មោះ [redacted] ទ្រិកគី និង បងរបស់គាត់ឈ្មោះ [redacted] ទ្រិកគី ([redacted] Trickey) បានផ្ញើរប្រាក់ ទាំងវេរតាមធនាគារ ទាំងឱ្យជាសាច់ប្រាក់សុទ្ធ ទៅឈ្មោះ នួន ស្រីទូច ដើម្បីទិញអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ។ មូលហេតុដែលលោក [redacted] ទ្រិកគី និង លោក [redacted] ទ្រិកគី មិនអាចមានឈ្មោះប័ណ្ណនៅពេលនោះ ដោយសារកត្តាពីរយ៉ាង គឺនៅពេលនោះឈ្មោះ [redacted] ស្រីទូច គឺត្រូវជាប្អូនថ្លៃរបស់លោក [redacted] ទ្រិកគី ទី២ ដោយសារតែលោកទាំងពីរគឺជាជនបរទេស ។ ដូចលោកចៅក្រមបានជ្រាបអំពីភស្តុតាងនៅក្នុងសំណុំរឿង អំពីរូបថតជាច្រើនដែលខ្ញុំបានដាក់នៅក្នុងសំណុំរឿង ដែលបង្ហាញអំពីទំនាក់ទំនង និង ការរស់នៅរបស់លោក [redacted] ទ្រិកគី និង លោក [redacted] ជាប្តីរបស់ឈ្មោះ [redacted] ស្រីទូច នៅលើទីតាំងអចលនវត្ថុនោះ គឺចាប់តាំងពីពេលដែលទិញអចលនវត្ថុនោះ គឺគាត់បានបង្កើតក្លឹបប្រដាល់ និង បានសាងសង់ផ្ទះនៅលើទីតាំងនោះផងដែរ។ រហូតមកដល់ចំណុចមួយដែល លោកស្រី [redacted] ស្រីទូច និង លោក [redacted] ទ្រិកគី ចាប់ផ្តើមមានទំនាក់ទំនងប្រេះឆារនៅក្នុងគ្រួសារ ។ លោក ចាស្ទីន ទ្រិកគី ក៏បានដាក់ពាក្យសុំដើម្បីសុំដីកាសម្រេចរក្សាការពារពីតុលាការ ដែលនៅក្នុងខ្លឹមសារនៃដីកាសម្រេចនោះ គឺបានហាមឃាត់ និង បានសម្រេចនូវខ្លឹមសារមួយចំនួន ដូចដែលមាននៅក្នុងភស្តុតាងដែលបានដាក់នៅក្នុងសំណុំរឿង ។ ការដែរតុលាការចេញដីកាសម្រេចរក្សាការពារឱ្យទៅលោក [redacted] និង លោក អាគុន សំអាងទៅលើទំនាក់ទំនងសិទ្ធិ និង ភាពលំបាកនូវការអនុវត្តប្រសិនបើភាគីម្ចាស់បំណុល ឈ្នះនៅក្នុងរឿងអង្គសេចក្តី ។ ភស្តុតាងដែលអាចបង្ហាញបានថា លោក [redacted] ទ្រិកគី ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុទាំងពីរកន្លែងនោះ គឺទី១ សាលក្រមរបស់សាលាដំបូងខេត្តកណ្តាល ទី២ លិខិតបញ្ជាក់អំពីសាលក្រមចូលជាស្ថាពរ ទី៣ រូបមន្តអនុវត្តសាលក្រម ទី៤ លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ពីឈ្មោះ [redacted] ស្រីទូច ទៅឱ្យលោក [redacted] សារុំ ដែលជាអ្នកតំណាងឱ្យលោក [redacted] ។ ដោយសារតែទំនាក់ទំនងប្រេះឆារ ទើបមានការដាក់រក្សារការពារ និង ដើររឿងអង្គសេចក្តី ។ ម្យ៉ាងវិញទៀតភស្តុតាងដែលអាចបញ្ជាក់ថា លោកស្រី [redacted] ស្រីទូច មិនមានជាម្ចាស់កម្មសិទ្ធិនៅក្នុងស្រុកខ្មែរនោះគឺ នៅក្នុងសេចក្តីថ្លែងការណ៍ជាភាសាអង់គ្លេស និង ភាសាខ្មែរ របស់លោកស្រី [redacted] ស្រីទូច ដែលបានអះអាង និង ឆ្លើយបំភ្លឺនៅចំពោះមុខចៅក្រមនៅប្រទេសអូស្ត្រាលី នៅក្នុងអំឡុងពេលនីតិវិធីដេញដោលក្នុងរឿងលែងលះគ្នា ដែលលោកស្រី [redacted] ស្រីទូច បានបញ្ជាក់ថា "ឪពុកលោក និង លោក ចាស្ទីន បានទិញអចលនវត្ថុចំនួន ៣កន្លែង នៅប្រទេសកម្ពុជា នៅក្នុងឆ្នាំ ២០១២ ខ្ញុំក៏សូមបញ្ជាក់ថាប្លង់ដីទាំង០៣កន្លែង គឺនៅឪពុករបស់ខ្ញុំ ចំពោះទ្រព្យទាំងបីខាងលើ គឺត្រូវប្តីរបស់ខ្ញុំ ឪពុកក្មេករបស់នាងខ្ញុំ ចូលលុយគ្នាដើម្បីទិញ ហើយពួកគាត់ទិញទ្រព្យទាំងនោះដាក់ឈ្មោះខ្ញុំ ពួកគាត់ដាក់ឈ្មោះខ្ញុំនៅពេលនោះ ព្រោះពួកគាត់ជាជនបរទេស ដូចនេះមិនអាចទិញទ្រព្យបានទេ ហើយខ្ញុំមិនបានចូលលុយទិញទ្រព្យនោះទេ" ។ នេះជាដំណើរការនៃការដាក់រក្សាការពារ និង ដំណើរការសំណុំរឿងអង្គសេចក្តី រហូតដល់ចៅក្រមចេញសាលក្រម ដែលបានសម្រេចនៅលើ ៣ ចំណុច គឺទី១ មោឃភាពទៅលើប័ណ្ណទាំងពីរ ២. ទទួលស្គាល់លោក [redacted] សារុំ ដែលជាអ្នកតំណាងឱ្យលោក ចាស្ទីន នោះជាម្ចាស់កម្មសិទ្ធិទៅលើដីទាំងពីរកន្លែង ទី៣. បង្គាប់ឱ្យឈ្មោះ [redacted] សារុំ ដែលជាតំណាងឱ្យលោក ចាស្ទីន ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិដីទាំងពីរប័ណ្ណ ។ រហូតដល់ផុតរយៈពេលប្តឹងតវ៉ា ប្តឹងជំទាស់ និង ប្តឹងឧទ្ធរណ៍ ឈានទៅដល់ការចេញនូវរូបមន្តអនុវត្ត និង លិខិតបញ្ជាក់សាលក្រមស្ថាពរ ។ តើសាលក្រមស្ថាពរចេញមុនពេល ឬ ក្រោយពេល



Scanned with CamScanner

មន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តលុបដីកាសម្រេចរក្សាការពារ ? គឺដីកាសម្រេចលុបចោលដីកាសម្រេចរក្សារពារ ចេញក្រោយពេលដែលសាលក្រមនោះចូលជាស្ថាពរ ។ សំណុំរឿងរក្សាការពារជាជាសំណុំរឿងរណបសំណុំរឿងអង្គសេចក្តីតែប៉ុណ្ណោះ ។ នៅពេលដែលសំណុំរឿងអង្គសេចក្តីចូលជាស្ថាពរនោះ គឺសំណុំរឿងរក្សាការពារគឺលែងមានភាពចាំបាច់ទៅហើយ ។ ជាក់ស្តែងនៅពេលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តលុបចោលដីកាសម្រេចរក្សាការពារនោះ គឺលោកមិនបានដឹងថាមានសាលក្រមស្ថាពរដែលបានទទួលស្គាល់ម្ចាស់បំណុលជាម្ចាស់អចលនទ្រព្យនោះទេ ប្រសិនបើលោកដឹង ខ្ញុំជឿជាក់ថាលោកនឹងមិនទៅអនុវត្តបែបនោះដែរ ។ ចំណុចដែលគួរកត់សម្គាល់នៅក្នុងដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ទី១ តើនៅពេលដែលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តនោះ តើលោកស្រី [redacted] ស្រីទូច មានវត្តមាននៅទីកន្លែងកើតហេតុដែរឬ ទេ? ប្រសិនបើលោកស្រីមិននៅកន្លែងកើតហេតុផង តើអាចចោទប្រកាន់លោក [redacted] វុទ្ធី មិនអនុវត្តសេចក្តីសម្រេចរបស់តុលាការបានដែរទេ ? ទី២ នៅពេលដែលចុះទៅអនុវត្តទាំងដែរមានឯកសារគតិយុត្តិដែលទទួលស្គាល់ភាគីម្ខាងជាម្ចាស់អចលនទ្រព្យ ហើយកំពុងឋិតនៅក្នុងដំណាក់កាលចុះបញ្ជីផ្ទេរកម្មសិទ្ធិផងដែរ ចំណុចទី៣ នៅក្នុងដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ក៏មិនបានសម្រេចថាប្រគល់អចលនវត្ថុឱ្យទៅភាគីណាដែរ គឺគ្រាន់តែលុបចោលដីកាសម្រេចរក្សាការពារដើមតែប៉ុណ្ណោះ ។ លោក [redacted] ទ្រិកគី មានឯកសារចំនួនពីរ ដែលបញ្ជាក់ថាលោក ចាស្ទីន មានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុទាំងពីរកន្លែងនោះគឺ ទី១ ដីកាសម្រេចរក្សាការពារ ទី២ សាលក្រមស្ថាពរដែលទទួលស្គាល់លោកចាស្ទីនជាម្ចាស់ ទើបគាត់ ប្រគល់សិទ្ធិឱ្យទៅលោក [redacted] វុទ្ធី ចូលទៅរស់នៅមើលថែរនៅលើទីតាំងដីនោះ ។ ជាការពិត នៅក្នុងប័ណ្ណកម្មសិទ្ធិទាំងពីរទីតាំងនោះ គឺមានឈ្មោះលោកស្រី [redacted] ស្រីទូច ជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែសាលក្រមស្ថាពររបស់សាលាដំបូងខេត្តកណ្តាលបានសម្រេចមោឃភាពចោលប័ណ្ណទាំងពីរនោះហើយពុំមានឯកសារគតិយុត្តិណាមួយ ដែលលុបនូវអំណាចសាលក្រមស្ថាពរនោះទេ ។ ហើយការប្តឹងជំនុំជម្រះសារជាថ្មី គឺប្តឹងក្រោយពេលនោះទេក្រោយពេលដែលសាលក្រមចូលស្ថាពរ ។ អង្គហេតុដែលប្តឹងសារជាថ្មី គឺពេលនោះ [redacted] ស្រីទូច មិនមែនជាម្ចាស់កម្មសិទ្ធិទាំងពីរកន្លែងនោះ ទៅហើយ ។ អង្គហេតុដែលចោទទាំងបីបទល្មើសលោក [redacted] វុទ្ធី មិនបានប្រព្រឹត្តដូចការចោទ ប្រកាន់ទាំងបីនោះទេ ព្រោះវត្តមានរបស់គាត់មាននៅលើទីតាំង គឺលោក [redacted] វុទ្ធី បានទទួលសិទ្ធិ ពីអ្នកមានសិទ្ធិម្ចាស់កម្មសិទ្ធិនៅលើដីនោះ ។ ចំពោះ បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ខ្ញុំគិតថាការចោទប្រកាន់នោះគឺអាចត្រឹមត្រូវបើកំឡុងពេលលោក [redacted] ស្រីទូច នៅជាម្ចាស់កម្មសិទ្ធិ លើដីនោះ ប៉ុន្តែពេលនោះ លោកស្រី [redacted] ស្រីទូច មិនមែនជាម្ចាស់កម្មសិទ្ធិនោះទេ ហើយនៅក្នុង ដីកាសម្រេចនោះមិនបានចាប់បង្ខំអ្នកនៅលើទីតាំងចេញពីទីតាំងខាងលើនោះដែរ ។ ចំពោះ បទហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត គឺអាចចោទប្រកាន់បាន លុះត្រាតែបុគ្គលនោះជាម្ចាស់ ហើយបុគ្គលនោះមានវត្តមាននៅកន្លែងកើតហេតុ ប៉ុន្តែនៅពេលនោះលោកស្រី [redacted] ស្រីទូច មិនមានវត្តមាន និង ពេលនោះមិន មែនជាម្ចាស់កម្មសិទ្ធិលើទីតាំងដីនោះទេ ។ ជាចុងក្រោយ ខ្ញុំជាមេធាវី ការពារសិទ្ធិឱ្យលោក [redacted] វុទ្ធី ស្នើសុំលោកចៅក្រម មេត្តាសម្រេចឱ្យលោក [redacted] វុទ្ធី រួចផុតពី បទចោទប្រកាន់ទាំងបី។

៨. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំគាំទ្រការលើកឡើងរបស់សហភាតាខ្ញុំ និង ស្នើសុំបន្ថែមពីលើសហភាតារបស់ខ្ញុំ ទី១ ការចោទប្រកាន់ពី បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ខ្ញុំសូមបន្ថែមថា កូនក្តីរបស់ខ្ញុំបានទទួលសិទ្ធិពីលោក ចាស្ទីន ដែល

ជាម្ចាស់សិទ្ធិលើទីតាំងដីនោះ ។ ហើយដីកាសម្រេចរក្សាការពារបានកំណត់ឋានៈជាបណ្តោះអាសន្ន ដោយបានកំណត់លោក ចាស្វីន ជាម្ចាស់កម្មសិទ្ធិនៅលើទីតាំងដីនោះ ។ ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារនោះ គឺគ្រាន់តែជាការលុបចោលដីកាសម្រេចដើម តែប៉ុណ្ណោះ ហើយក៏មិនមែនប្រគល់សិទ្ធិឱ្យអ្នកណាម្នាក់ជាម្ចាស់កម្មសិទ្ធិនោះទេ ។ កូនក្តីខ្ញុំ ជាអ្នកមើលថែរក្សានៅលើទីតាំងដីនោះតែប៉ុណ្ណោះ ។ ចំពោះការចោទប្រកាន់ពី បទរំលោភលើលំនៅដ្ឋាន គឺមិនត្រឹមត្រូវនោះទេ ដោយសារអចលនវត្ថុនោះគឺជារបស់លោក ចាស្វីន ហើយ លោក ចាស្វីន បានប្រគល់សិទ្ធិឱ្យកូនក្តីខ្ញុំ ចូលទៅមើលថែទាំនៅលើទីតាំងដីផ្ទះនោះ ។ ចំពោះការចោទប្រកាន់កូនក្តីរបស់ខ្ញុំ ពីបទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដូចដែលកូនក្តីរបស់ខ្ញុំបានលើកឡើងថា កូនក្តីរបស់ខ្ញុំពិតជាបានស្នើសុំទុករយៈពេលមួយសប្តាហ៍ ប៉ុន្តែមកដល់ពេលកំណត់មិនឃើញមានអាជ្ញាសាលាចុះមកទីតាំងម្តងទៀត ដើម្បីប្រគល់ទទួលទីតាំងនោះ សួរថាប្រសិនបើកូនក្តីខ្ញុំចាកចេញពីទីតាំងនោះ តើនៅពេលមានបញ្ហាអ្វីមួយកើតឡើង តើមានអ្នកណាទទួលខុសត្រូវ ។ ក្នុងនាមខ្ញុំជា មេធាវីការពារសិទ្ធិឱ្យកូនក្តី ខ្ញុំបាទស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទទាំងបី ។

៩. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំគាំទ្រការលើកឡើងរបស់សហភាតាខ្ញុំ និង ស្នើសុំធ្វើសេចក្តីសន្និដ្ឋានបន្ថែមពីលើសហភាតារបស់ខ្ញុំ ទី១ ការចោទប្រកាន់ពីបទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ខ្ញុំសូមបន្ថែមថា កូនក្តីរបស់ខ្ញុំបានទទួលសិទ្ធិពីលោក ចាស្វីន ដែល ជាម្ចាស់សិទ្ធិលើទីតាំងដីនោះ ។ ហើយដីកាសម្រេចរក្សាការពារបានកំណត់ឋានៈជាបណ្តោះអាសន្ន ដោយបានកំណត់លោក ចាស្វីន ជាម្ចាស់កម្មសិទ្ធិនៅលើទីតាំងដីនោះ ។ ចំពោះដីកាសម្រេច លុបចោលដីកាសម្រេចរក្សាការពារនោះ គឺគ្រាន់តែជាការលុបចោលដីកាសម្រេចដើម តែប៉ុណ្ណោះ ហើយក៏មិនមែនប្រគល់សិទ្ធិឱ្យអ្នកណាម្នាក់ជាម្ចាស់កម្មសិទ្ធិនោះទេ ។ កូនក្តីខ្ញុំ ជាអ្នកមើលថែរក្សា នៅលើទីតាំងដីនោះតែប៉ុណ្ណោះ ។ ចំពោះការចោទប្រកាន់ពីបទរំលោភលើលំនៅដ្ឋាន គឺមិនត្រឹមត្រូវនោះទេ ដោយសារអចលនវត្ថុនោះគឺជារបស់លោក ចាស្វីន ហើយ លោក ចាស្វីន បានប្រគល់សិទ្ធិឱ្យកូនក្តីខ្ញុំ ចូលទៅមើលថែទាំនៅលើទីតាំងដីផ្ទះនោះ ។ ចំពោះការចោទប្រកាន់កូនក្តីរបស់ខ្ញុំ ពីបទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដូចដែលកូនក្តីរបស់ខ្ញុំបានលើកឡើងថា កូនក្តីរបស់ខ្ញុំពិតជាបានស្នើសុំទុករយៈពេលមួយសប្តាហ៍ ប៉ុន្តែមកដល់ពេលកំណត់មិនឃើញមានអាជ្ញាសាលា ចុះមកទីតាំងម្តងទៀត ដើម្បីប្រគល់ទទួលទីតាំងនោះ សួរថាប្រសិនបើកូនក្តីខ្ញុំចាកចេញពីទីតាំងនោះ តើនៅពេលមានបញ្ហាអ្វីមួយកើតឡើង តើមានអ្នកណាទទួលខុសត្រូវ ។ ក្នុងនាមខ្ញុំជា មេធាវីការពារសិទ្ធិឱ្យកូនក្តី ខ្ញុំបាទស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទទាំងបី ។

១០. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំសូមគាំទ្រការលើកឡើងរបស់សហភាតាខ្ញុំ និង ស្នើសុំបន្ថែមពីលើសហភាតារបស់ខ្ញុំ លោកស្រី [redacted] ស្រីទូច មិនមែនជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យទាំងពីរទីតាំងនោះទេ ហើយដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ នោះគឺគ្រាន់តែជាការលុបចោលរក្សាការពារដើម មិនមែនជាការប្រគល់សិទ្ធិលើកម្មសិទ្ធិទៅឱ្យអ្នកណាជាម្ចាស់កម្មសិទ្ធិនោះទេ ។ លោកស្រី [redacted] ស្រីទូច មិនមានវត្តមាននៅប្រទេសកម្ពុជានោះទេ នៅពេលកើតហេតុ ។ ហើយនៅពេលដែលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តសេចក្តីសម្រេចលុបចោលដីកាសម្រេចរក្សាការពារនោះ កូនក្តីរបស់ខ្ញុំបាទមិនបានតវ៉ាអ្វី

នោះទេ ពោលគឺបានសហការជាមួយមន្ត្រីអាជ្ញាសាលា ដូចនេះខ្ញុំតំណាងឱ្យកូនក្តីខ្ញុំស្នើសុំ តុលាការសម្រេចលើកលែងចោទប្រកាន់ដល់កូនក្តីរបស់ខ្ញុំ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងលើសំណុំរឿងនេះ

## សំអាងហេតុ

១. យោងតាមដីកាសម្រេចរក្សាការពារ លេខ ០៤ "ឆ" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល បានអនុញ្ញាតឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី មានសិទ្ធិគ្រប់គ្រង ថែរក្សាអាស្រ័យផល លើទីតាំងដីវិវាទជាបណ្តោះអាសន្ន ប៉ុន្តែក្រោយមកតុលាការបានចេញ ដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ លេខ ០៦ "ឆ" ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ដើម្បីរំលាយការកាន់កាប់របស់ជនជាប់ចោទ ឈ្មោះ [redacted] វុទ្ធី វិញ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានសំណូមពរ និង សន្យាជាមួយមន្ត្រីអាជ្ញាសាលា ដែលបានចុះទៅអនុវត្តសេចក្តីសម្រេចលុបដីកាសម្រេចរក្សាការពារ ឱ្យមន្ត្រីអាជ្ញាសាលាទុករយៈពេលឱ្យខ្លួនមួយសប្តាហ៍ ដើម្បីរើសម្ភារៈចេញពីទីតាំង ដែលមន្ត្រីអាជ្ញាសាលាចុះទៅអនុវត្តនោះ ។ ផ្ទុយទៅវិញក្រោយដល់កាលកំណត់ ដែលជនជាប់ចោទបានស្នើសុំ ដើម្បីរើសម្ភារៈចេញពីទីតាំងនោះ បែរជាជនជាប់ចោទមិនគោរព និងអនុវត្តតាមការសន្យារបស់ខ្លួន ដើម្បីរើសម្ភារៈចេញពីទីតាំងនោះ ហើយបន្ថែមពីនោះទៀត ជនជាប់ចោទបានបញ្ជាឱ្យបក្សពួករបស់ខ្លួន បន្តស្នាក់នៅលើទីតាំងនោះដដែល ។ ដូចនេះតុលាការ យល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានប្រព្រឹត្ត បទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដោយមានចម្លើយ និង ភស្តុតាងស៊ីសង្វាក់ ។

២. យោងតាមដីកាដំណោះស្រាយលេខ ៨០៩/២២ "ធ" ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ឃើញថាជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ត្រូវបានបញ្ជូនមកជំនុំជម្រះ ពីបទរំលោភលើលំនៅដ្ឋាន និងបទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប៉ុន្តែយោងតាមសាលក្រម លេខ ០៥៩ "ង" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល លិខិតបញ្ជាក់សាលក្រមចូលជាស្ថាពរ លេខ ១៦៧ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ រូបមន្តអនុវត្ត លេខ ១១៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ និង លិខិតផ្តុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ លេខ ៤៦ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឃើញថាតុលាការបានសម្រេចឱ្យឈ្មោះ [redacted] ត្រិកគី (Justin Trickey) ជាម្ចាស់កម្មសិទ្ធិអចលនវត្ថុ ដែលមានប័ណ្ណសំគាល់កាន់កាប់ដីធ្លីលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ហើយបានមោឃភាព



Scanned with CamScanner

ប័ណ្ណសំគាល់កាន់កាប់ដីធ្លីលេខ ក.ណ ០១៣៦១២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ក.ណ ០១៨១០៤ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលនាំឱ្យដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាកម្មសិទ្ធិករទេ ក្នុងអំឡុងពេលសាលក្រមលេខ ០៥៩ "ង" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ កំពុងមានអានុភាព ។ ក្នុងចំណុចនេះ ក៏តុលាការពិនិត្យឃើញថា សាលក្រម លេខ ០៥៩ "ង" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១៩ នេះ បានចូលជាស្ថាពរដែរ (ចូលជាស្ថាពរមុនកាលបរិច្ឆេទប្រព្រឹត្តបទល្មើស) ហើយទោះបីជាមានដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសារជាថ្មី លេខ ៩៧២ រ.ឋ/២២ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ ក៏ដោយ ក៏តុលាការពិនិត្យឃើញថា ដីកាសម្រេចនេះ កើតមានឡើងក្រោយពេលកាលបរិច្ឆេទនៃ ការប្រព្រឹត្តបទល្មើសដែរ ហើយរហូតមកដល់ពេលនេះ ក៏ពុំទាន់មានសេចក្តីសម្រេចណាមួយជំនួស សាលក្រម លេខ ០៥៩ "ង" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់ សាលាដំបូងខេត្តកណ្តាលទេ។

៣. យោងតាមចម្លើយសាក្សី ចម្លើយជនជាប់ចោទ ព្រមទាំងពិនិត្យឯកសារភស្តុតាងផ្សេងៗ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានចូលគ្រប់គ្រង កាន់កាប់លើទីតាំងដី និង លំនៅដ្ឋាន ទាំងពីរនោះ (ទីតាំងទី១ ស្ថិតនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង ទីតាំងទី២ ស្ថិតនៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល) ចាប់តាំងពីឆ្នាំ២០១១ មកម្ល៉េះ គឺមុននឹងវិវាទលើទីតាំងដីទាំងពីរ កើតឡើងទៅទៀត ដោយការចេញចូលក្នុងទីតាំងដី និង លំនៅដ្ឋានទាំងពីរ គឺពុំមានការប្រើហិង្សាបង្ខិតបង្ខំ គំរាមកំហែង ឬ ឧបាយកលណាមួយនោះទេ ។ ម្យ៉ាងវិញទៀត ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានទទួលការអនុញ្ញាតពីលោក [redacted] ត្រិកគី (Justin Trickey) ដែលម្ចាស់កម្មសិទ្ធិតាមអំណាចសាលក្រមស្ថាពរលេខ ០៥៩ "ង" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ក្នុងការគ្រប់គ្រងកាន់កាប់អចលនវត្ថុមានវិវាទ ។

៤. យោងតាមសំអាងហេតុទី២ និង ទី៣ ខាងលើ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ពុំបានប្រព្រឹត្តអំពើរំលោភលើលំនៅដ្ឋាន និង អំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត នោះទេ ដោយមានចម្លើយ និង ភស្តុតាង ស៊ីសង្វាក់គ្នា ។

៥. ជនជាប់ចោទជានីតិជន និង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៦. ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានដឹងយ៉ាងច្បាស់ថាអំពើមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ គឺជាអំពើខុសច្បាប់ តែខ្លួននៅតែប្រព្រឹត្ត ។ ដូចនេះតុលាការ យល់ឃើញថាជនជាប់ចោទមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ។

៧. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ពី បទមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ និង ប្តឹងសុំតុលាការសម្រេចឱ្យជនជាប់ចោទរួចខ្លួនពី បទរំលោភលើលំនៅដ្ឋាន និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ។ តុលាការ នឹងពិចារណា សម្រេចស្របតាម អង្គហេតុ និង អង្គច្បាប់ ។



Scanned with CamScanner

៨. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំតុលាការសម្រេចឱ្យជនជាប់ចោទ រួចខ្លួនពីបទចោទប្រកាន់ទាំងស្រុង ប៉ុន្តែតុលាការយល់ឃើញថា ការស្នើសុំរបស់មេធាវី មិនត្រឹមត្រូវទាំងស្រុងនោះទេ ដោយមានមូលហេតុដូចមានក្នុងសំអាងហេតុទី ១ ទី២ ទី៣ និង ទី៤ ខាងលើ ។

៩. ក្រោយពីឆ្លងកាត់ការពិភាក្សាដេញដោល និង ពិនិត្យភស្តុតាងនានា តុលាការយល់ឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] វុទ្ធី ភេទប្រុស អាយុ ៤១ឆ្នាំ ប្រព្រឹត្ត **បទមិនអនុវត្តសេចក្តីសម្រេចតុលាការ** ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល នៅអំឡុងឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៥២៣ កថាខណ្ឌ ២ នៃក្រមព្រហ្មទណ្ឌ ។ ប៉ុន្តែមិនបាន **ប្រព្រឹត្តបទរំលោភលើលំនៅដ្ឋាន និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល នៅអំឡុងឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសស្រប តាមបញ្ញត្តិមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាលទេ។

១០. សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំតុលាការសម្រេចឱ្យជនជាប់ចោទ សងប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លាអាមេរិក នាំឱ្យតុលាការគប្បីពិចារណា ទៅលើការទាមទារសំណងនេះក្នុងកម្រិតសមរម្យ ។

## **ហេតុដូច្នេះសម្រេច**

១. ផ្តន្ទាទោសឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ ៤១ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ ពី បទមិនអនុវត្តសេចក្តីសម្រេចតុលាការ ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល នៅអំឡុងឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាម បញ្ញត្តិមាត្រា ៥២៣ កថាខណ្ឌ ២ នៃក្រមព្រហ្មទណ្ឌ ។

២. ឱ្យជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ភេទប្រុស អាយុ ៤១ឆ្នាំ (សាវតាជាតិខាងលើ) រួចខ្លួនពី **បទរំលោភលើលំនៅដ្ឋាន និង បទហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល និង នៅភូមិព្រែកឡុង សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល នៅអំឡុងឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។



Scanned with CamScanner

៣. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ភេទប្រុស អាយុ ៤១ឆ្នាំ (សាវតាជាតិខាងលើ) សងសំណង ខូចខាតចំនួន ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ស្រីទូច ។

សាលក្រមនេះ ចំពោះមុខដើមបណ្ដឹង ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] វុទ្ធី ។ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមនីតិវិធីច្បាប់។

ថ្ងៃពុធ ១១ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កណ្ដាល, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**
ហត្ថលេខា និង ត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១ កើត ខែបឋមាសាឍ ឆ្នាំថោះ ចត្វាស័ក ព.ស ២៥៦៧
កណ្ដាល, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]